

# ដំណាំប៉េងប៉ោះ

*ដោយ:អគ្គនាយកដ្ឋានកសិកម្ម*

Tomato ( Lycopersicon esculentum Mill )

ប៉េងប៉ោះជាដំណាំបន្លែមួយអាចប្រើប្រាស់សំរាប់បរិភោគដោយចំអិន និងស្រស់ ឬអាចប្រើវាលាយបញ្ចូលជាមួយបន្លែគ្រប់ប្រភេទ។ ផ្លែវាសំបូរទៅដោយជីវជាតិ និងវីតាមីនជាច្រើន ជាពិសេសសំបូរទៅដោយវីតាមីនសេ (Vitamin C) និងសារធាតុរ៉ែជាច្រើនទៀតដូចជា កាល់ស្យូម ផូស្វ័រ និងដែក ។ វាជាប្រភពវីតាមីនដែលមានតម្លៃថោក និងគុណភាពខ្ពស់ ជាពិសេសសម្រាប់ផ្តល់ជាអាហារប្រចាំថ្ងៃដល់កុមារ និងសម្រាប់ការលូតលាស់របស់វា។ ផ្លែប៉េងប៉ោះប្រើជាទឹកជ្រលក់និងជាថ្នាំសម្រាប់ជំនួយស្បែក។ តាមការពិតប៉េងប៉ោះមានផ្ទុកសារធាតុ Gamna-amino butyric (GABA) ខ្ពស់ វាអាចបញ្ចុះសម្ពាធឈាម និងជំងឺបេះដូងបានទៀតផង។

* សមស្របនឹងអាកាសធាតុត្រូពិចដោយសីតុណ្ហភាពនៅពេលថ្ងៃចាប់ពី១៥-២៥អង្សាសេ។
* ពេលវេលាប្រសើរបំផុតសម្រាប់ដាំគឺចាប់ពីខែតុលា ដល់មករា ដោយសីតុណ្ហភាពនៅពេលយប់ត្រជាក់។
* ដំណាំប៉េងប៉ោះ ផ្តល់ផ្លែច្រើនអតិបរិមាគឺសីតុណ្ហភាពនៅពេលយប់មានរហូតដល់ ១៦ អង្សាសេ ប៉ុន្តែប្រសិនបើអាកាសធាតុនៅពេលថ្ងៃមានរហូតដល់ ៣២ អង្សាសេ ការកាន់ផ្លែត្រូវបានថយចុះ។
* អាចដាំបាននៅលើប្រភេទដីជាច្រើន ប៉ុន្តែត្រូវមានជីជាតិ និងស្រោះទឹកល្អ។ កម្រិតប៉េហាស់សមស្រប គឺ ៥.៥-៦.៨ ។
* ត្រូវការពារដីពីពពួកណេម៉ាតូត បាក់តេរី និងប្រភេទជំងឺក្នុងដីផ្សេងៗទៀត។
* មិនគួរដាំដំណាំនេះបន្ទាប់ពីដំណាំថ្នាំជក់ ដំឡូង ម្ទេស ឬត្រប់។

## ១. បច្ចេកទេសដាំដុះ

### ក. ការជ្រើសរើសពូជ:

ការជ្រើសរើសពូជជាកត្តាសំខាន់ដំបូងសម្រាប់ការដាំដុះកំណត់ទិន្នផល និងតម្រូវការទីផ្សារ។ កត្តាសំខាន់ៗដែលត្រូវកំណត់ជ្រើសរើសមាន ៖

* ពូជមានប្រភពច្បាស់លាស់( ពូជក្នុងស្រុក ឬពូជបង្កាត់ )
* ពូជមានអាយុកាលត្រឹមត្រូវ
* ពូជដែលមានដំណុះល្អ ៨៥-៩០%
* ពូជសុទ្ធល្អ
* ពូជធន់នឹងអាកាសធាតុ សត្វល្អិត និងជំងឺ

ចំពោះពូជបង្កាត់មិនអាចទុកពូជបន្តបានទេ

### ខ. ការរៀបចំថ្នាលបណ្តុះកូន

* គ្រាប់ពូជ ២៥០-៣០០ ក្រាម ប្រើក្នុងផ្ទៃដី ១ហិកតា
* ទទឹងថ្នាល ១ម និងប្រវែងបណ្តោយតាមតម្រូវការ នៅរដូវប្រាំង កម្ពស់រង ១៥-២០ ស.ម និងរដូវវស្សា ២០-៣០ ស.ម
* ច្របល់ផេះអង្កាម ៣០០ក្រាម និងជីកំប៉ុស្ត ៥០០ក្រាមក្នុងផ្ទៃដី១ម៉ែត្រការ៉េ
* ស្រោចទឹកឱ្យជោគ រួចឆូតចង្អូររាក់ កាត់ទទឹងរងចន្លោះជួរ ១០ សង្ទីម៉ែត្រ

- សាបគ្រាប់ប៉េងប៉ោះ ឱ្យបានស្តើងក្នុងជម្រៅ ០.៥ ស.ម និងគ្រប ឬលុបដីឱ្យបានជិតល្អ
- កាត់ចំបើងជាកង់ៗ រួចគ្របពីលើរង និងស្រោចទឹកឱ្យជោគល្អ។

**គ. ការបណ្តុះកូន:**

- គ្រាប់ប៉េងប៉ោះហាលថ្ងៃ ១-២ ម៉ោង ត្រាំទឹកក្តៅឧណ្ហៗ ប្រហែល ៣៥ អង្សាសេ រយៈពេល២០ នាទី
- ផ្អាប់ក្នុងក្រណាត់សើម ៤០-៤៨ម៉ោងទើបអាចសាបលើថ្នាល។
- ១០ថ្ងៃក្រោយសាប គេអាចដករំលោះ (ធីវ) កូនប៉េងប៉ោះខ្លះទុកឱ្យរង្វើល និងមានសុខភាពល្អ។ គេអាចយក ទៅដាំបានក្នុងរយៈពេល ១៨-២៥ថ្ងៃក្រោយសាប។



ថ្នាលបណ្តុះកូនប៉េងប៉ោះ

**ឃ. ការរៀបចំដី:**

- ការភ្ជួរ និងរាស់ដីឱ្យបាន ២ដង
- ហាលដីឱ្យស្ងួតល្អរយៈពេលពី ១០-១៥ថ្ងៃ
- លើករងកម្ពស់ពី ២៥-៣០ ស.ម ទទឹងរង ១២០ស.ម និងចន្លោះរង ៧៥ ស.ម

**ង. ការដាំដុះ:**

- ចន្លោះគុម្ព ៧០ ស.ម ចន្លោះជួរ ១ ម និងដាំក្នុង១គុម្ព/១ដើម។
- ត្រូវស្រោចទឹកលើថ្នាលឱ្យជោគមុនពេលដកកូនយកទៅដាំ (ដាំនៅពេលរសៀលឬពេលមេឃត្រជាក់)។
- ដាំរួចត្រូវស្រោចទឹកឱ្យជោគ។



របៀបដាំដំណាំប៉េងប៉ោះ

## ២. ការថែទាំ

**ក. ការជ្រួយដី និងកំចាត់ស្មៅ:**

- ជ្រួយដីត្រូវធ្វើឡើងក្រោយដាំ ១០-១២ថ្ងៃ។
- ក្រោយដាំ ៣៥-៤០ ថ្ងៃ ត្រូវដកស្មៅចេញ និងហាមជ្រួយដី។

**ខ. ការស្រោចទឹក:**

- ការស្រោចទឹកជាប្រចាំនៅពេលព្រឹក និងពេលល្ងាច
- ត្រូវរក្សាសំណើម ៦០-៧០ % ប្រសិនបើមានសំណើមខ្ពស់ អាចកើតឡើងនូវពពួកជំងឺក្នុងដី

**គ. ការដោតចំណារ និងកាត់មែក:**

- ការដោតចំណារធ្វើឡើងនៅមុនពេលប៉េងប៉ោះចេញផ្កា
- ការកាត់រំលោះមែកផ្នែកខាងក្រោមដើម្បីឱ្យមានខ្យល់ចេញចូល រក្សាសំណើម និងបាត់បង់

ជីជាតិ

⁕ កាត់បន្ថយការឆ្លងជំងឺ និង សត្វល្អិតចង្រៃ។

**ឃ. ការដាក់ជី:**

⁕ **លើកទី១** ៖ ការប្រើជីទ្រាប់បាត ដាក់ជីកំប៉ុស្តចំនួន ០.៥ – ១ គីឡូក្រាម លាយជាមួយជី (១៥.១៥.១៥) ចំនួន ៤-៥ក្រាម និងជីអ៊ុយរ៉េ ២ក្រាម ក្នុងមួយរណ្តៅ។

⁕ **លើកទី២** ៖ ក្រោយដាំបាន ១០-១៥ថ្ងៃ ប្រើជី (១៥.១៥.១៥) ចំនួន ២-៣ក្រាម លាយជាមួយទឹក ២០លីត្រ។

⁕ **លើទី៣** : ពេលប៉េងបោះមុនចេញផ្កា ត្រូវបន្តការដាក់ជីបំប៉នបន្ថែមទៀត ជីអ៊ុយរ៉េ ៥-១០ក្រាម និងជី (១៥-១៥-១៥) ១៥-២០ក្រាមក្នុងមួយរណ្តៅ។

## ៣. ការគ្រប់គ្រងជំងឺ និងសត្វល្អិត

### ក. ជំងឺសំខាន់ៗ:

ជំងឺផ្សិត ជំងឺបាក់តេរី និងជំងឺវីរុស។

⁕ ជំងឺផ្សិតមានច្រើនប្រភេទ ដូចជា ផ្សិតនៅលើផ្លែ លើដើម គល់ លើស្លឹក: ជំងឺផ្សិតខ្មៅ ជំងឺដាំស្លឹកសំលាក ជំងឺម្សៅដាំស្លឹក ជំងឺ រលាកគល់ ជំងឺរលួយឫស និងគល់ និងជំងឺផ្សិតគល់។

⁕ ជំងឺបាក់តេរីមាន ដូចជា ជំងឺអុចខ្មៅលើដើម ស្លឹក និងផ្លែ

⁕ ជំងឺវីរុសមាន ដូចជា ជំងឺរួញត្រួយពណ៌

**វិធានការការពារ និងកម្ចាត់**

ជ្រើសរើសពូជធន់ ផ្លាស់ប្តូរមុខដំណាំ ឬផ្អាកដាំដុះ ១-២ឆ្នាំ បន្ថយការស្រោចទឹក សម្អាត ស្មៅ ជាប្រចាំ កាត់ស្លឹក និងមែកឱ្យស្រឡះជ្រើសរើសរដូវសមស្រប។

### ខ. សត្វល្អិតសំខាន់ៗ :

មានសត្វល្អិតជាច្រើនប្រភេទបំផ្លាញស្លឹកផ្កា




ជំងឺឆេះស្លឹក ( Late blight )




ជំងឺខ្លោចផ្លែ ( Late blight on fruit )




ជំងឺរលួយផ្លែ ( Bukeye Fruit Rot )




ជំងឺស្រពោនដើម ( Fusarium wilt )




ជំងឺជាំស្លឹក ( Leaf mold )